ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
និយ័តករគណនេយ្យនិងសវនកម្ម

# ស្តង់ដាគណនេយ្យសាធារណៈកម្ពុជា

## Cambodian Public Sector Accounting Standards

# CPSAS 14

## ព្រឹត្តិការណ៍បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍

## Event after the Reporting Date

កក្កដា ២០២៦

ក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិសម្រាប់វិស័យសាធារណៈ
International Public Sector Accounting Standards Board (IPSASB)

IPSAS®

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ........ សហវ. ......

# ប្រកាស
## ស្តីពី
## ការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យសាធារណៈកម្ពុជា លេខ ៣ ស្តីពីគោលនយោបាយគណនេយ្យ ការផ្លាស់ប្តូរការប៉ាន់ស្មានគណនេយ្យ និងកំហុសឆ្គង លេខ ១៤ ស្តីពីព្រឹត្តិការណ៍បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ និង លេខ ២០ ស្តីពីការលាតត្រដាងអំពីភាគីពាក់ព័ន្ធ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
## និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ន/ស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ ២៨៩ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ
- យោងតាមសំណើរបស់និយ័តករគណនេយ្យនិងសវនកម្ម

## សម្រេច

**ប្រការ១.-**

ត្រូវបានដាក់ឱ្យអនុវត្តនូវស្តង់ដាគណនេយ្យសាធារណៈកម្ពុជាចំនួន ៣ ដូចខាងក្រោម៖

១. ស្តង់ដាគណនេយ្យសាធារណៈកម្ពុជា លេខ ៣ ស្តីពីគោលនយោបាយគណនេយ្យ ការផ្លាស់ប្តូរការប៉ាន់ស្មានគណនេយ្យ និងកំហុសឆ្គង

២. ស្តង់ដាគណនេយ្យសាធារណៈកម្ពុជា លេខ ១៤ ស្តីពីព្រឹត្តិការណ៍បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ និង

៣. ស្តង់ដាគណនេយ្យសាធារណៈកម្ពុជា លេខ ២០ ស្តីពីការលាតត្រដាងអំពីភាគីពាក់ព័ន្ធ។

ស្តង់ដាគណនេយ្យសាធារណៈកម្ពុជាដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ ត្រូវបានរៀបចំឡើងដោយផ្អែកលើមូលដ្ឋាន"ស្តង់ដាគណនេយ្យអន្តរជាតិសម្រាប់វិស័យសាធារណៈមូលដ្ឋានបង្គរ" ដែលចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិសម្រាប់វិស័យសាធារណៈ។

ស្តង់ដាគណនេយ្យសាធារណៈកម្ពុជាដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ មានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ២.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល។

**ប្រការ៣.-**

និយ័តករគណនេយ្យនិងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ អាចចេញគោលការណ៍ណែនាំស្តីពីការអនុវត្តស្តង់ដាគណនេយ្យសាធារណៈកម្ពុជាដូចមានចែងក្នុងប្រការ១ នៃប្រកាសនេះ និងផ្តល់ការគាំទ្រផ្នែកបច្ចេកទេសស្តង់ដាគណនេយ្យដល់គណនេយ្យករសាធារណៈ និងតួអង្គពាក់ព័ន្ធ តាមការចាំបាច់។

ក្នុងករណីចាំបាច់ និយ័តករគណនេយ្យនិងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ អាចធ្វើបច្ចុប្បន្នភាពស្តង់ដាគណនេយ្យសាធារណៈកម្ពុជា ដើម្បីឱ្យស្របតាមបរិបទអន្តរជាតិ។

**ប្រការ៤.-**

អគ្គនាយកដ្ឋានរតនាគារជាតិ ក្នុងតួនាទីជាគណនេយ្យករសាធារណៈ ត្រូវជ្រើសរើស រៀបចំ និងអនុវត្តគោលនយោបាយគណនេយ្យ អនុលោមតាមស្តង់ដាគណនេយ្យសាធារណៈកម្ពុជា លេខ ៣ ស្តីពីគោលនយោបាយគណនេយ្យ ការផ្លាស់ប្តូរការប៉ាន់ស្មានគណនេយ្យ និងកំហុសឆ្គង ដូចមានចែងក្នុងប្រការ១ នៃប្រកាសនេះ និងត្រូវធានាថា គោលនយោបាយគណនេយ្យ ត្រូវបានអនុវត្តប្រកបដោយសង្គតិភាពចំពោះគ្រប់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល។

អគ្គនាយកដ្ឋានរតនាគារជាតិ ត្រូវរៀបចំនីតិវិធីក្នុងការប្រមូលផ្តុំព័ត៌មានពីគ្រប់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ពាក់ព័ន្ធនឹងព្រឹត្តិការណ៍ដែលបានកើតឡើងបន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ និងមុនពេលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានអនុញ្ញាតឱ្យបោះផ្សាយ ព្រមទាំងកំណត់អត្តសញ្ញាណ ធ្វើគណនេយ្យកម្ម កែតម្រូវ និងលាតត្រដាងព័ត៌មានអំពីព្រឹត្តិការណ៍ទាំងនោះ អនុលោមតាមស្តង់ដាគណនេយ្យសាធារណៈកម្ពុជា លេខ ១៤ ស្តីពីព្រឹត្តិការណ៍បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ ដូចមានចែងក្នុងប្រការ១ នៃប្រកាសនេះ។

អគ្គនាយកដ្ឋានរតនាគារជាតិ ត្រូវរៀបចំយន្តការសមស្របដើម្បីកំណត់អត្តសញ្ញាណរបស់ភាគីពាក់ព័ន្ធក្នុងវិស័យសាធារណៈ និងត្រូវប្រមូលផ្តុំព័ត៌មានពាក់ព័ន្ធនឹងប្រតិបត្តិការនិងទំនាក់ទំនងរបស់ភាគីពាក់ព័ន្ធ ដោយភ្ជាប់ជាមួយនឹងក្របខណ្ឌពេលវេលាជាក់លាក់ក្នុងការប្រមូលព័ត៌មានទាំងនេះពីគ្រប់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដោយវាយតម្លៃអំពីភាពពេញលេញ និងភាពជាសារវន្តនៃព័ត៌មានទាំងនេះ ដើម្បីលាតត្រដាងក្នុងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ អនុលោមតាមស្តង់ដាគណនេយ្យសាធារណៈកម្ពុជា លេខ ២០ ស្តីពីការលាតត្រដាងអំពីភាគីពាក់ព័ន្ធ ដូចមានចែងក្នុងប្រការ១ នៃប្រកាសនេះ។

**ប្រការ៥.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រសួង អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ក្រសួង ស្ថាប័នដូចបានកំណត់ក្នុងប្រការ២ និងគ្រប់អ្នកពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៦ កើត ខែ ទុតិយាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កក្កដា គ.ស.២០២៦

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ស្តង់ដាគណនេយ្យសាធារណៈកម្ពុជា លេខ ១៤ ស្តីពីព្រឹត្តិការណ៍បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍

## ការទទួលស្គាល់

ស្តង់ដាគណនេយ្យសាធារណៈកម្ពុជា (CPSAS) លេខ ១៤ ត្រូវបានរៀបចំដោយផ្អែកលើស្តង់ដាគណនេយ្យអន្តរជាតិសម្រាប់វិស័យសាធារណៈ (IPSAS) ១៤, ព្រឹត្តិការណ៍បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍, ចេញពីសៀវភៅសេចក្តីប្រកាសគណនេយ្យអន្តរជាតិសម្រាប់វិស័យសាធារណៈ របស់ ក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិសម្រាប់វិស័យសាធារណៈ (IPSASB) ដែលបានចេញផ្សាយដោយ សហព័ន្ធគណនេយ្យករអន្តរជាតិ (IFAC) នៅក្នុងខែកក្កដា ឆ្នាំ២០២០ ហើយត្រូវបានប្រើប្រាស់ដោយមានការអនុញ្ញាតពីសហព័ន្ធគណនេយ្យករអន្តរជាតិ។

សៀវភៅសេចក្តីប្រកាសគណនេយ្យអន្តរជាតិសម្រាប់វិស័យសាធារណៈ ©2020 ដោយសហព័ន្ធគណនេយ្យករអន្តរជាតិ (IFAC)។ សូមរក្សាសិទ្ធិគ្រប់យ៉ាង។

ចេញផ្សាយដោយ៖
និយ័តករគណនេយ្យនិងសវនកម្ម
ផ្លូវលេខ ៩២, សង្កាត់វត្តភ្នំ, ខណ្ឌដូនពេញ, រាជធានីភ្នំពេញ
លេខទូរស័ព្ទ៖ +(855) 23 882 111
អ៊ីម៉ែល៖ info@acar.gov.kh
គេហទំព័រ៖ www.acar.gov.kh

# ស្តង់ដាគណនេយ្យសាធារណៈកម្ពុជា លេខ ១៤ ស្តីពីព្រឹត្តិការណ៍បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍

## មាតិកា

កថាខណ្ឌ


គោលបំណង ..... ១

វិសាលភាព ..... ២-៤

និយមន័យ ..... ៥

ការអនុញ្ញាតឱ្យបោះផ្សាយរបាយការណ៍ហិរញ្ញវត្ថុ ..... ៦-៨

ការទទួលស្គាល់ និងការវាស់វែង ..... ៩-១៦

ព្រឹត្តិការណ៍កែតម្រូវ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ ..... ១០-១១

ព្រឹត្តិការណ៍មិនកែតម្រូវ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ ..... ១២-១៣

ភាគលាភ ឬ ការបែងចែកប្រហាក់ប្រហែល ..... ១៤-១៦

និរន្តរភាព ..... ១៧-២៥

ការរៀបចំរចនាសម្ព័ន្ធឡើងវិញ ..... ២៥

ការលាតត្រដាង ..... ២៦-៣១

ការលាតត្រដាងអំពីកាលបរិច្ឆេទនៃការអនុញ្ញាតឱ្យបោះផ្សាយ ..... ២៦-២៧

ការធ្វើបច្ចុប្បន្នភាពការលាតត្រដាងអំពីលក្ខខណ្ឌ នាកាលបរិច្ឆេទរាយការណ៍ ..... ២៨-២៩

ការលាតត្រដាងអំពីព្រឹត្តិការណ៍មិនកែតម្រូវ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ ..... ៣០-៣១

# គោលបំណង

១. គោលបំណងនៃស្តង់ដានេះ គឺដើម្បីកំណត់អំពី៖

(ក) ពេលវេលាដែលស្ថាប័នមួយគួរកែតម្រូវរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន សម្រាប់ព្រឹត្តិការណ៍បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ និង

(ខ) ការលាតត្រដាងដែលស្ថាប័នមួយគួរផ្តល់អំពីកាលបរិច្ឆេទ ដែលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានអនុញ្ញាតឱ្យបោះផ្សាយ និងអំពីព្រឹត្តិការណ៍បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍។

ស្តង់ដានេះក៏តម្រូវផងដែរថា ស្ថាប័នមិនគួររៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ផ្អែកលើមូលដ្ឋាននិរន្តរភាពនោះទេ ប្រសិនបើព្រឹត្តិការណ៍បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍បង្ហាញថា ការសន្មតអំពីនិរន្តរភាព ពុំមានភាពសមស្រប។

# វិសាលភាព

២. ស្ថាប័នមួយដែលរៀបចំ និងដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុតាមមូលដ្ឋានគណនេយ្យបង្គរ ត្រូវអនុវត្តស្តង់ដានេះក្នុងការធ្វើគណនេយ្យកម្មនិងការលាតត្រដាងអំពីព្រឹត្តិការណ៍បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍។

៣. [លុបចេញ]

៤. [លុបចេញ]

# និយមន័យ

៥. វាក្យសព្ទដែលបានប្រើក្នុងស្តង់ដានេះ ត្រូវបានកំណត់និយមន័យ ដូចខាងក្រោម៖

<u>ព្រឹត្តិការណ៍បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍</u> គឺជាព្រឹត្តិការណ៍ទាំងឡាយណា ទាំងមានអំណោយផល និងមិនអំណោយផល ដែលកើតឡើងចន្លោះរវាងកាលបរិច្ឆេទរាយការណ៍ និងកាលបរិច្ឆេទដែលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានអនុញ្ញាតឱ្យបោះផ្សាយ។ ព្រឹត្តិការណ៍ចំនួន ២ ប្រភេទ អាចត្រូវបានកំណត់៖

(ក) ព្រឹត្តិការណ៍ទាំងឡាយណាដែលផ្តល់ភស្តុតាងនៃលក្ខខណ្ឌ ដែលបានកើតឡើងនាកាលបរិច្ឆេទរាយការណ៍ (ព្រឹត្តិការណ៍កែតម្រូវ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍) និង

(ខ) ព្រឹត្តិការណ៍ទាំងឡាយណាដែលបង្ហាញអំពីលក្ខខណ្ឌ ដែលបានកើតឡើងបន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ (ព្រឹត្តិការណ៍មិនកែតម្រូវ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍)។

វាក្យសព្ទដែលបានកំណត់និយមន័យក្នុងស្តង់ដា CPSAS ផ្សេងទៀត ត្រូវបានប្រើក្នុងស្តង់ដានេះ ដោយមានអត្ថន័យដូចគ្នានឹងស្តង់ដាទាំងនោះដែរ ហើយត្រូវបានកំណត់ឡើងវិញនៅក្នុង *សទ្ទានុក្រមនៃវាក្យសព្ទដែលបានកំណត់និយមន័យ* ដែលត្រូវបានបោះពុម្ពផ្សាយដាច់ដោយឡែក។

## ការអនុញ្ញាតឱ្យបោះផ្សាយរបាយការណ៍ហិរញ្ញវត្ថុ

៦. ដើម្បីកំណត់ថាតើព្រឹត្តិការណ៍ណាមួយ បំពេញតាមនិយមន័យនៃព្រឹត្តិការណ៍បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ ចាំបាច់ត្រូវកំណត់ទាំងកាលបរិច្ឆេទរាយការណ៍ និងកាលបរិច្ឆេទដែលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានអនុញ្ញាតឱ្យបោះផ្សាយ។ កាលបរិច្ឆេទរាយការណ៍ គឺជាថ្ងៃចុងក្រោយនៃការិយ-បរិច្ឆេទរាយការណ៍ដែលរបាយការណ៍ហិរញ្ញវត្ថុជាប់ពាក់ព័ន្ធ។ កាលបរិច្ឆេទនៃការអនុញ្ញាតឱ្យបោះផ្សាយ គឺជាកាលបរិច្ឆេទដែលរបាយការណ៍ហិរញ្ញវត្ថុបានទទួលការអនុម័តពីបុគ្គល ឬ ស្ថាប័នមានសមត្ថកិច្ច ដើម្បីបញ្ចប់របាយការណ៍ទាំងនោះសម្រាប់ការបោះផ្សាយ។ មតិសវនកម្មត្រូវបានផ្តល់លើរបាយការណ៍ហិរញ្ញវត្ថុដែលបានបញ្ចប់ទាំងនោះ។ ព្រឹត្តិការណ៍បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ គឺជាព្រឹត្តិការណ៍ទាំងអស់ ទាំងអំណោយផល និងមិនអំណោយផល ដែលកើតឡើងចន្លោះរវាងកាលបរិច្ឆេទរាយការណ៍ និងកាលបរិច្ឆេទដែលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានអនុញ្ញាតឱ្យបោះផ្សាយ ទោះបីជាព្រឹត្តិការណ៍ទាំងនោះកើតឡើងបន្ទាប់ពី (ក) ការបោះផ្សាយសេចក្តីប្រកាសអំពីអតិរេក ឬ ឱនភាព, (ខ) ការអនុញ្ញាតឱ្យបោះផ្សាយរបាយការណ៍ហិរញ្ញវត្ថុរបស់ស្ថាប័នក្រោមការគ្រប់គ្រងមួយ ឬ (គ) ការបោះផ្សាយព័ត៌មានដែលបានជ្រើសរើសដទៃផ្សេងទៀតពាក់ព័ន្ធនឹងរបាយការណ៍ហិរញ្ញវត្ថុ។

៧. ដំណើរការពាក់ព័ន្ធក្នុងការរៀបចំ និងអនុញ្ញាតឱ្យបោះផ្សាយរបាយការណ៍ហិរញ្ញវត្ថុ អាចប្រែប្រួលទៅតាមប្រភេទស្ថាប័នផ្សេងៗគ្នាដែលស្ថិតនៅក្នុងយុត្តាធិការតែមួយ និងរវាងយុត្តាធិការផ្សេងគ្នា។ ដំណើរការនេះអាចអាស្រ័យលើចរិតលក្ខណៈរបស់ស្ថាប័ន, រចនាសម្ព័ន្ធរបស់ស្ថាប័នគ្រប់គ្រង និងលក្ខខណ្ឌចាំបាច់តាមផ្លូវច្បាប់ណាមួយដែលពាក់ព័ន្ធនឹងស្ថាប័ននោះ ព្រមទាំងនីតិវិធីដែលត្រូវអនុវត្តក្នុងការរៀបចំ និងបញ្ចប់របាយការណ៍ហិរញ្ញវត្ថុ។ ការទទួលខុសត្រូវសម្រាប់ការអនុម័តរបាយការណ៍ហិរញ្ញវត្ថុរបស់ភ្នាក់ងាររាជរដ្ឋាភិបាលនីមួយៗ អាចអាស្រ័យទៅលើប្រធានភ្នាក់ងារហិរញ្ញវត្ថុថ្នាក់កណ្តាល (ឬ មន្ត្រីហិរញ្ញវត្ថុ ឬ មន្ត្រីគណនេយ្យជាន់ខ្ពស់ ដូចជា អ្នកត្រួតពិនិត្យ ឬ គណនេយ្យករសាធារណៈ)។ ការទទួលខុសត្រូវសម្រាប់ការអនុម័តរបាយការណ៍ហិរញ្ញវត្ថុរួមរបស់រាជរដ្ឋាភិបាលទាំងមូល អាចអាស្រ័យរួមគ្នាលើប្រធានភ្នាក់ងារហិរញ្ញវត្ថុថ្នាក់កណ្តាល (ឬ មន្ត្រីហិរញ្ញវត្ថុជាន់ខ្ពស់ ដូចជា អ្នកត្រួតពិនិត្យ ឬ គណនេយ្យករសាធារណៈ) និងរដ្ឋមន្ត្រីហិរញ្ញវត្ថុ (ឬ ប្រហាក់ប្រហែល)។

៨. ក្នុងករណីមួយចំនួន ជាជំហានចុងក្រោយក្នុងដំណើរការនៃការអនុម័ត ស្ថាប័នមួយត្រូវបានតម្រូវឱ្យដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនទៅកាន់ស្ថាប័នដទៃផ្សេងទៀត (ឧទាហរណ៍ ស្ថាប័ននីតិប្បញ្ញត្តិ ដូចជា រដ្ឋសភា ឬ ក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន)។ ស្ថាប័ននេះអាចមានសិទ្ធិអំណាចតម្រូវឱ្យមានការកែប្រែទៅលើរបាយការណ៍ហិរញ្ញវត្ថុដែលបានរងសវនកម្ម។ ក្នុងករណីផ្សេងទៀត ការដាក់បញ្ជូនរបាយការណ៍ទៅកាន់ស្ថាប័នដទៃ អាចគ្រាន់តែជាពិធីការ ឬ ដំណើរការផ្លូវការតែប៉ុណ្ណោះ ហើយស្ថាប័នដទៃនោះប្រហែលជាពុំមានសិទ្ធិអំណាចតម្រូវឱ្យមានការកែប្រែទៅលើរបាយការណ៍នោះទេ។ កាលបរិច្ឆេទនៃការអនុញ្ញាតឱ្យបោះផ្សាយរបាយការណ៍ហិរញ្ញវត្ថុ នឹងត្រូវបានកំណត់ក្នុងបរិបទរបស់យុត្តាធិការជាក់លាក់។

## ការទទួលស្គាល់ និងការវាស់វែង

៩. នៅក្នុងការិយបរិច្ឆេទចន្លោះរវាងកាលបរិច្ឆេទរាយការណ៍ និងកាលបរិច្ឆេទនៃការអនុញ្ញាតឱ្យបោះផ្សាយ, មន្ត្រីរាជរដ្ឋាភិបាលដែលបានជ្រើសតាំង អាចប្រកាសអំពីចេតនារបស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹងបញ្ហាជាក់លាក់។ ថាតើចេតនារបស់រាជរដ្ឋាភិបាលដែលបានប្រកាសទាំងនេះ អាចនឹងតម្រូវឱ្យមានការទទួលស្គាល់ជាព្រឹត្តិការណ៍កែតម្រូវ ឬក៏អត់ អាចអាស្រ័យលើ (ក) ថាតើចេតនាទាំងនេះផ្តល់ព័ត៌មានបន្ថែមអំពីលក្ខខណ្ឌដែលកើតឡើងនាកាលបរិច្ឆេទរាយការណ៍ និង (ខ) ថាតើមានភស្តុតាងគ្រប់គ្រាន់ដែលចេតនាទាំងនោះអាច និងត្រូវបានបំពេញដែរឬទេ។ ក្នុងករណីភាគច្រើន ការប្រកាសចេតនារបស់រាជរដ្ឋាភិបាល នឹងមិននាំឱ្យមានការទទួលស្គាល់ព្រឹត្តិការណ៍កែតម្រូវទេ។ ជំនួសមកវិញ ចេតនាទាំងនោះជាទូទៅអាចបំពេញលក្ខណៈសម្បត្តិគ្រប់គ្រាន់ សម្រាប់ការលាតត្រដាងជាព្រឹត្តិការណ៍មិនកែតម្រូវ។

## ព្រឹត្តិការណ៍កែតម្រូវ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍

១០. **ស្ថាប័នត្រូវកែតម្រូវចំនួនទឹកប្រាក់ដែលបានទទួលស្គាល់ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ដើម្បីឆ្លុះបញ្ចាំងពីព្រឹត្តិការណ៍កែតម្រូវ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍។**

១១. ខាងក្រោមគឺជាឧទាហរណ៍នៃព្រឹត្តិការណ៍កែតម្រូវ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ ដែលតម្រូវឱ្យស្ថាប័នមួយកែតម្រូវចំនួនទឹកប្រាក់ដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ឬ ទទួលស្គាល់ធាតុដែលមិនត្រូវបានទទួលស្គាល់ពីមុនៈ

(ក) ការដោះស្រាយសំណុំរឿងនៅតុលាការ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ ដែលបញ្ជាក់ថាស្ថាប័នមានកាតព្វកិច្ចបច្ចុប្បន្នមួយ នាកាលបរិច្ឆេទរាយការណ៍។ ស្ថាប័នកែតម្រូវសំវិធានធនដែលបានទទួលស្គាល់ពីមុនណាមួយ ពាក់ព័ន្ធនឹងសំណុំរឿងតុលាការនេះ ដោយអនុលោមតាមស្តង់ដា CPSAS ១៩, *សំវិធានធន, បំណុលយថាហេតុ និងទ្រព្យសកម្មយថាហេតុ* ឬ ទទួលស្គាល់សំវិធានធនថ្មីមួយ។ ស្ថាប័នមិនធ្វើការលាតត្រដាងអំពីបំណុលយថាហេតុទេ ពីព្រោះការដោះស្រាយសំណុំរឿងផ្តល់ភស្តុតាងបន្ថែមដែលអាចយកមកពិចារណា ដោយអនុលោមតាមកថាខណ្ឌ ២៤ នៅក្នុងស្តង់ដា CPSAS ១៩។

(ខ) ការទទួលបានព័ត៌មានបន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ ដែលបានបង្ហាញថា ទ្រព្យសកម្មមួយបានធ្លាក់ចុះតម្លៃនាកាលបរិច្ឆេទរាយការណ៍ ឬ បង្ហាញថា ចំនួនទឹកប្រាក់នៃការខាតបង់ពីការថយចុះតម្លៃដែលបានទទួលស្គាល់ពីមុនសម្រាប់ទ្រព្យសកម្មនោះ ចាំបាច់ត្រូវធ្វើការកែតម្រូវ។ ឧទាហរណ៍ៈ

(i) ការក្ស័យធនរបស់កូនបំណុល ដែលកើតឡើងបន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ ជាធម្មតាបញ្ជាក់ថា កូនបំណុលមានការធ្លាក់ចុះតម្លៃឥណទាននាចុងការិយបរិច្ឆេទរាយការណ៍ និង

(ii) ការលក់សន្និធិបន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ អាចផ្តល់ភស្តុតាងអំពីតម្លៃសុទ្ធដែលអាចទទួលបាន នាកាលបរិច្ឆេទរាយការណ៍។

(គ) ការកំណត់ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ អំពីថ្លៃដើមទ្រព្យសកម្មដែលបានទិញ ឬចំណូលពីទ្រព្យសកម្មដែលបានលក់ មុនកាលបរិច្ឆេទរាយការណ៍

(ឃ) ការកំណត់ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ អំពីចំនួនទឹកប្រាក់នៃចំណូលដែលប្រមូលបាននៅក្នុងអំឡុងការិយបរិច្ឆេទរាយការណ៍ ដែលត្រូវចែកជាមួយរដ្ឋាភិបាលផ្សេងទៀត ក្រោមកិច្ចព្រមព្រៀងចែកចំណូលជាធរមាន នៅក្នុងអំឡុងការិយបរិច្ឆេទរាយការណ៍

(ង) ការកំណត់ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ អំពីការទូទាត់ប្រាក់រង្វាន់សមិទ្ធកម្មទៅកាន់បុគ្គលិក ប្រសិនបើស្ថាប័នមានកាតព្វកិច្ចស្ម័គ្រចិត្ត ឬ កាតព្វកិច្ចផ្លូវច្បាប់បច្ចុប្បន្ននាកាលបរិច្ឆេទរាយការណ៍ ដើម្បីធ្វើការទូទាត់ទាំងនេះ ជាលទ្ធផលនៃព្រឹត្តិការណ៍មុនកាលបរិច្ឆេទនោះ និង

(ច) ការរកឃើញនូវការក្លែងបន្លំ ឬ កំហុសឆ្គងដែលបង្ហាញថា របាយការណ៍ហិរញ្ញវត្ថុមិនមានភាពត្រឹមត្រូវ។

## ព្រឹត្តិការណ៍មិនកែតម្រូវ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍

**១២. ស្ថាប័នមួយមិនត្រូវកែតម្រូវចំនួនទឹកប្រាក់ដែលបានទទួលស្គាល់ក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ដើម្បីឆ្លុះបញ្ចាំងពីព្រឹត្តិការណ៍មិនកែតម្រូវ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍នោះទេ។**

១៣. ខាងក្រោមគឺជាឧទាហរណ៍នៃព្រឹត្តិការណ៍មិនកែតម្រូវ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍៖

(ក) ការធ្លាក់ចុះតម្លៃសមស្របនៃទ្រព្យចន្លោះរវាងកាលបរិច្ឆេទរាយការណ៍ និងកាលបរិច្ឆេទដែលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានអនុញ្ញាតឱ្យបោះផ្សាយ នៅពេលស្ថាប័នបានអនុវត្តគោលការណ៍មួយក្នុងការវាយតម្លៃទ្រព្យឡើងវិញជាទៀងទាត់ ទៅតាមតម្លៃសមស្រប។ ជាធម្មតា ការធ្លាក់ចុះតម្លៃសមស្របមិនជាប់ទាក់ទងនឹងលក្ខខណ្ឌនៃទ្រព្យនាកាលបរិច្ឆេទរាយការណ៍នោះទេ ប៉ុន្តែ ឆ្លុះបញ្ចាំងពីកាលៈទេសៈដែលបានកើតឡើងក្នុងការិយបរិច្ឆេទបន្ទាប់។ ដូចនេះ ទោះបីជាបានអនុវត្តគោលនយោបាយក្នុងការវាយតម្លៃទ្រព្យឡើងវិញជាទៀងទាត់ក៏ដោយ ស្ថាប័នមិនត្រូវធ្វើការកែតម្រូវចំនួនទឹកប្រាក់ដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនសម្រាប់ទ្រព្យឡើយ។ ស្រដៀងគ្នានេះដែរ ស្ថាប័នមិនធ្វើបច្ចុប្បន្នភាពចំនួនទឹកប្រាក់ដែលបានលាតត្រដាងសម្រាប់ទ្រព្យ គិតត្រឹមកាលបរិច្ឆេទរាយការណ៍នោះទេ ទោះបីជាស្ថាប័នអាចនឹងចាំបាច់ត្រូវផ្តល់ការលាតត្រដាងបន្ថែម ស្របតាមកថាខណ្ឌ ២៩ ក៏ដោយ និង

(ខ) នៅពេលស្ថាប័នដែលមានភារកិច្ចដំណើរការកម្មវិធីផ្តល់សេវាដល់សហគមន៍ជាក់លាក់ បានសម្រេចចិត្តផ្តល់ ឬ បែងចែកអត្ថប្រយោជន៍បន្ថែម ដោយផ្ទាល់ ឬ ប្រយោល ទៅកាន់អ្នកចូលរួមក្នុងកម្មវិធីទាំងនោះ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ ប៉ុន្តែមុនពេលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានអនុម័ត។ ស្ថាប័នមិនត្រូវធ្វើការកែតម្រូវចំណាយដែលបានទទួលស្គាល់

នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន នៅក្នុងការិយបរិច្ឆេទរាយការណ៍បច្ចុប្បន្ននោះទេ ទោះបីជាអត្ថប្រយោជន៍បន្ថែម អាចបំពេញបានតាមលក្ខខណ្ឌសម្រាប់ការលាតត្រដាងជាព្រឹត្តិការណ៍មិនកែតម្រូវ ស្របតាមកថាខណ្ឌ ២៩ ក៏ដោយ។

## ភាគលាភ ឬ ការបែងចែកប្រហាក់ប្រហែល

**១៤. ប្រសិនបើស្ថាប័នមួយប្រកាសអំពីភាគលាភ ឬ ការបែងចែកប្រហាក់ប្រហែល បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍, ស្ថាប័នមិនត្រូវទទួលស្គាល់ការបែងចែកទាំងនោះជាបំណុលនាកាលបរិច្ឆេទរាយការណ៍នោះទេ។**

១៥. ភាគលាភអាចកើតមានក្នុងវិស័យសាធារណៈ នៅពេល ឧទាហរណ៍ ស្ថាប័នសាធារណៈមួយគ្រប់គ្រង និងរួមបញ្ចូលរបាយការណ៍ហិរញ្ញវត្ថុរបស់ស្ថាប័នសាធារណៈដែលមានលក្ខណៈពាណិជ្ជកម្មមួយ ដែលមានភាគកម្មនៃភាពជាម្ចាស់កម្មសិទ្ធិខាងក្រៅ ទៅកាន់បុគ្គលដែលខ្លួនទូទាត់ភាគលាភឱ្យ។ លើសពីនេះ ស្ថាប័នសាធារណៈមួយចំនួនអនុវត្តក្របខណ្ឌនៃការគ្រប់គ្រងហិរញ្ញវត្ថុមួយ ឧទាហរណ៍ គំរូ "អ្នកទិញ-អ្នកផ្តល់" ដែលតម្រូវឱ្យស្ថាប័នទាំងនោះធ្វើការទូទាត់ការបែងចែកប្រាក់ចំណូលទៅកាន់ស្ថាប័នគ្រប់គ្រងរបស់ខ្លួន ដូចជា រាជរដ្ឋាភិបាលថ្នាក់កណ្តាល។

១៦. ប្រសិនបើភាគលាភ ឬ ការបែងចែកប្រហាក់ប្រហែលទៅកាន់ម្ចាស់ ត្រូវបានប្រកាស (ឧទាហរណ៍ ភាគលាភ ឬ ការបែងចែកប្រហាក់ប្រហែល ត្រូវបានអនុម័តសមស្រប និងមិនស្ថិតក្រោមការសម្រេចរបស់ស្ថាប័នតទៅទៀត) បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ ប៉ុន្តែមុនពេលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានអនុញ្ញាតឱ្យបោះផ្សាយ, ភាគលាភ ឬ ការបែងចែកប្រហាក់ប្រហែល មិនត្រូវបានទទួលស្គាល់ជាបំណុលនាកាលបរិច្ឆេទរាយការណ៍នោះទេ ពីព្រោះមិនមានកាតព្វកិច្ចកើតមានឡើងនាពេលនោះ។ ភាគលាភ ឬ ការបែងចែកប្រហាក់ប្រហែលទាំងនេះ ត្រូវលាតត្រដាងក្នុងកំណត់សម្គាល់ ដោយអនុលោមតាមស្តង់ដា CPSAS ១។ ភាគលាភ និងការបែងចែកប្រហាក់ប្រហែល មិនរួមបញ្ចូលផលពីដើមទុននោះទេ។

# និរន្តរភាព

១៧. ស្ថាប័ននីមួយៗចាំបាច់ត្រូវពិចារណាអំពីការកំណត់ថាតើការសន្មតអំពីនិរន្តរភាពមានភាពសមស្រប ដែរឬទេ។ ទោះបីជាយ៉ាងនេះក្តី ការវាយតម្លៃអំពីនិរន្តរភាព ហាក់មានការជាប់ពាក់ព័ន្ធច្រើនសម្រាប់ស្ថាប័ននីមួយៗ ជាជាងសម្រាប់រាជរដ្ឋាភិបាលទាំងមូល។ ឧទាហរណ៍ ភ្នាក់ងាររាជរដ្ឋាភិបាលមួយ អាចមិនមាននិរន្តរភាព ពីព្រោះរាជរដ្ឋាភិបាលដែលភ្នាក់ងារនោះស្ថិតក្រោម បានសម្រេចចិត្តផ្ទេរសកម្មភាពទាំងអស់របស់ខ្លួនទៅកាន់ភ្នាក់ងាររាជរដ្ឋាភិបាលផ្សេងទៀត។ ទោះបីជាយ៉ាងណាក៏ដោយ ការរៀបចំរចនាសម្ព័ន្ធឡើងវិញនេះ មិនមានផលប៉ះពាល់ដល់ការវាយតម្លៃអំពីនិរន្តរភាពសម្រាប់រាជរដ្ឋាភិបាលខ្លួនឯងនោះទេ។

**១៨. ស្ថាប័នមួយមិនត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ដោយផ្អែកលើមូលដ្ឋាននិរន្តរភាពនោះទេ ប្រសិនបើបុគ្គលដែលទទួលខុសត្រូវក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ឬ ស្ថាប័នគ្រប់គ្រងបានកំណត់ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ថា (ក) មានចេតនាជម្រះបញ្ជីស្ថាប័ន ឬបញ្ឈប់ប្រតិបត្តិការ ឬ (ខ) ពុំមានជម្រើសអ្វីផ្សេងក្រៅពីធ្វើដូច្នេះ។**

១៩. ក្នុងការវាយតម្លៃថាតើការសន្មតអំពីនិរន្តរភាពមានភាពសមស្របឬទេសម្រាប់ស្ថាប័នមួយ, បុគ្គលដែលទទួលខុសត្រូវក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និង/ឬ ស្ថាប័នគ្រប់គ្រង ចាំបាច់ត្រូវពិចារណាអំពីកត្តាផ្សេងៗជាច្រើន។ កត្តាទាំងនោះនឹងរួមមានសមិទ្ធផលបច្ចុប្បន្ននិងសមិទ្ធផលរំពឹងទុករបស់ស្ថាប័ន, ការរៀបចំរចនាសម្ព័ន្ធអង្គភាពចាត់តាំងឡើងវិញដែលត្រូវបានប្រកាស ឬ អាចកើតមានឡើងណាមួយ, លទ្ធភាពនៃការផ្តល់មូលនិធិបន្តរបស់រាជរដ្ឋាភិបាល និងប្រសិនបើចាំបាច់, ប្រភពចម្បងនៃការផ្តល់មូលនិធិជំនួស។

២០. ក្នុងករណីស្ថាប័នមានប្រតិបត្តិការរបស់ខ្លួនពឹងផ្អែកភាគច្រើនលើការផ្តល់មូលនិធិជាថវិកា, បញ្ហាអំពីនិរន្តរភាពជាទូទៅកើតមានឡើង តែនៅពេលរាជរដ្ឋាភិបាលប្រកាសចេតនារបស់ខ្លួនដើម្បីបញ្ឈប់ការផ្តល់មូលនិធិទៅឱ្យស្ថាប័នប៉ុណ្ណោះ។

២១. ស្ថាប័នសាធារណៈមួយចំនួនអាចត្រូវបានតម្រូវឱ្យពឹងផ្អែកទាំងស្រុង ឬ ពឹងផ្អែកភាគច្រើនលើការផ្តល់មូលនិធិដោយខ្លួនឯង និងដើម្បីប្រមូលមកវិញនូវថ្លៃដើមនៃទំនិញនិងសេវាពីអ្នកប្រើប្រាស់។ សម្រាប់ស្ថាប័នណាមួយបែបនេះ ការចុះខ្សោយនៃលទ្ធផលកិច្ចប្រតិបត្តិការនិងស្ថានភាពហិរញ្ញវត្ថុបន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ អាចបង្ហាញអំពីតម្រូវការមួយ ដើម្បីពិចារណាថាតើការសន្មតអំពីនិរន្តរភាពនៅតែមានភាពសមស្របដែរឬយ៉ាងណា។

២២. ប្រសិនបើការសន្មតអំពីនិរន្តរភាពលែងមានភាពសមស្របតទៅទៀត ស្តង់ដានេះតម្រូវឱ្យស្ថាប័នឆ្លុះបញ្ចាំងពីការពិតនេះនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន។ ផលប៉ះពាល់នៃការផ្លាស់ប្តូរបែបនេះនឹងអាស្រ័យលើកាលៈទេសៈជាក់លាក់របស់ស្ថាប័ន ឧទាហរណ៍ ថាតើប្រតិបត្តិការនឹងត្រូវបានផ្ទេរទៅស្ថាប័នរាជរដ្ឋាភិបាលផ្សេងទៀត, ត្រូវបានលក់ ឬ ជម្រះបញ្ជីដែរឬទេ។ ការវិនិច្ឆ័យត្រូវបានតម្រូវក្នុងការកំណត់ថាតើការផ្លាស់ប្តូរតម្លៃយោងនៃទ្រព្យសកម្មនិងបំណុល ត្រូវបានតម្រូវដែរឬទេ។

២៣. នៅពេលការសន្មតអំពីនិរន្តរភាពលែងមានភាពសមស្របតទៅទៀត វាក៏មានភាពចាំបាច់ផងដែរដើម្បីពិចារណាថាតើការផ្លាស់ប្តូរកាលៈទេសៈនាំឱ្យមានការកើតឡើងនូវបំណុលបន្ថែម ឬ បង្កើតឱ្យមានលក្ខខណ្ឌក្នុងកិច្ចសន្យាបំណុល ដែលនាំឱ្យមានការធ្វើចំណាត់ថ្នាក់ឡើងវិញនៃបំណុលជាក់លាក់មួយចំនួនជាបំណុលរយៈពេលខ្លី។

២៤. ស្តង់ដា CPSAS ១ តម្រូវឱ្យមានការលាតត្រដាងជាក់លាក់ ប្រសិនបើ៖

(ក) របាយការណ៍ហិរញ្ញវត្ថុមិនត្រូវបានរៀបចំផ្អែកលើមូលដ្ឋាននិរន្តរភាពទេ។ ស្តង់ដា CPSAS ១ តម្រូវថា នៅពេលរបាយការណ៍ហិរញ្ញវត្ថុមិនត្រូវបានរៀបចំផ្អែកលើមូលដ្ឋាននិរន្តរភាពទេ ការពិតនេះត្រូវធ្វើការលាតត្រដាង ជាមួយគ្នានឹងមូលដ្ឋានដែលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើង និងហេតុផលដែលស្ថាប័នមិនត្រូវបានពិចារណាថាមាននិរន្តរភាព ឬ

(ខ) បុគ្គលដែលទទួលខុសត្រូវក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ បានដឹងអំពីភាពមិនប្រាកដ-ប្រជាជាសារវន្តពាក់ព័ន្ធនឹងព្រឹត្តិការណ៍ ឬ លក្ខខណ្ឌដែលអាចនាំឱ្យមានមន្ទិលជាដុំកំភួនទៅលើសមត្ថភាពរបស់ស្ថាប័នដើម្បីបន្តជានិរន្តរភាព។ ព្រឹត្តិការណ៍ ឬ លក្ខខណ្ឌដែលតម្រូវឱ្យមានការលាតត្រដាង អាចកើតមានឡើង បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍។ ស្តង់ដា CPSAS ១ តម្រូវឱ្យមានការលាតត្រដាងអំពីភាពមិនប្រាកដប្រជាទាំងនោះ។

## ការរៀបចំរចនាសម្ព័ន្ធឡើងវិញ

២៥. នៅពេលការរៀបចំរចនាសម្ព័ន្ធឡើងវិញដែលបានប្រកាសបន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ បំពេញតាមនិយមន័យនៃព្រឹត្តិការណ៍មិនកែតម្រូវ, ការលាតត្រដាងសមស្របត្រូវបានធ្វើឡើង អនុលោមតាមស្តង់ដានេះ។ ការណែនាំអំពីការទទួលស្គាល់សំវិធានធនដែលជាប់ពាក់ព័ន្ធនឹងការរៀបចំរចនាសម្ព័ន្ធឡើងវិញ អាចរកបាននៅក្នុងស្តង់ដា CPSAS ១៩។ ដោយសារការរៀបចំរចនាសម្ព័ន្ធឡើងវិញជាប់ពាក់ព័ន្ធនឹងការបញ្ចេញចោលនូវសមាសធាតុមួយរបស់ស្ថាប័ន, ការបោះបង់នេះមិនបាននាំមកនូវសំណួរអំពីសមត្ថភាពរបស់ស្ថាប័នដើម្បីបន្តជានិរន្តរភាពនោះទេ។ ទោះបីជាយ៉ាងណា នៅពេលការរៀបចំរចនាសម្ព័ន្ធឡើងវិញដែលបានប្រកាសបន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ មានន័យថា ស្ថាប័នលែងមាននិរន្តរភាពតទៅទៀត, នោះ ចរិតលក្ខណៈ និងចំនួនទឹកប្រាក់នៃទ្រព្យសកម្មនិងបំណុលដែលបានទទួលស្គាល់ អាចមានការផ្លាស់ប្តូរ។

# ការលាតត្រដាង

## ការលាតត្រដាងអំពីកាលបរិច្ឆេទនៃការអនុញ្ញាតឱ្យបោះផ្សាយ

២៦. **ស្ថាប័នត្រូវលាតត្រដាងអំពីកាលបរិច្ឆេទដែលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានអនុញ្ញាតឱ្យបោះផ្សាយ និងបុគ្គលដែលបានផ្តល់ការអនុញ្ញាតនោះ។ ប្រសិនបើស្ថាប័នដទៃទៀតមានសិទ្ធិអំណាចកែតម្រូវរបាយការណ៍ហិរញ្ញវត្ថុបន្ទាប់ពីការបោះផ្សាយ, ស្ថាប័នត្រូវលាតត្រដាងអំពីការពិតនោះ។**

២៧. វាមានសារៈសំខាន់សម្រាប់អ្នកប្រើប្រាស់ ដើម្បីដឹងអំពីពេលវេលាដែលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានអនុញ្ញាតឱ្យបោះផ្សាយ នៅពេលរបាយការណ៍ហិរញ្ញវត្ថុមិនឆ្លុះបញ្ចាំងពីព្រឹត្តិការណ៍បន្ទាប់ពីកាលបរិច្ឆេទនេះ។ វាក៏មានសារៈសំខាន់សម្រាប់អ្នកប្រើប្រាស់ផងដែរ ដើម្បីដឹងអំពីកាលៈទេសៈដ៏កម្រដែលបុគ្គល ឬ ស្ថាប័នណាមួយមានសិទ្ធិអំណាចក្នុងការកែតម្រូវរបាយការណ៍ហិរញ្ញវត្ថុបន្ទាប់ពីបានបោះផ្សាយ។ ឧទាហរណ៍អំពីបុគ្គល ឬ ស្ថាប័នដែលអាចមានសិទ្ធិអំណាចកែតម្រូវរបាយការណ៍ហិរញ្ញវត្ថុបន្ទាប់ពីបានបោះផ្សាយ មានដូចជា រដ្ឋមន្ត្រី, រាជរដ្ឋាភិបាលដែលស្ថាប័នស្ថិតនៅក្រោម, រដ្ឋសភា ឬ ស្ថាប័នតំណាងដែលត្រូវបានជ្រើសតាំងមួយ។ ប្រសិនបើការផ្លាស់ប្តូរត្រូវបានធ្វើឡើង, របាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានកែតម្រូវ គឺជាសំណុំថ្មីនៃរបាយការណ៍ហិរញ្ញវត្ថុ។

## ការធ្វើបច្ចុប្បន្នភាពការលាតត្រដាងអំពីលក្ខខណ្ឌ នាកាលបរិច្ឆេទរាយការណ៍

**២៨. ប្រសិនបើស្ថាប័នទទួលបានព័ត៌មាន បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ ប៉ុន្តែមុនពេលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានអនុញ្ញាតឱ្យបោះផ្សាយ អំពីលក្ខខណ្ឌដែលបានកើតឡើង នាកាលបរិច្ឆេទរាយការណ៍, ស្ថាប័នត្រូវធ្វើបច្ចុប្បន្នភាពការលាតត្រដាងដែលជាប់ពាក់ព័ន្ធនឹងលក្ខខណ្ឌទាំងនេះ បន្ទាប់ពីទទួលបានព័ត៌មានថ្មី។**

២៩. ក្នុងករណីមួយចំនួន ស្ថាប័នចាំបាច់ត្រូវធ្វើបច្ចុប្បន្នភាពការលាតត្រដាងក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ដើម្បីឆ្លុះបញ្ចាំងពីព័ត៌មានដែលទទួលបាន បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ ប៉ុន្តែមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានអនុញ្ញាតឱ្យបោះផ្សាយ ទោះបីជានៅពេលព័ត៌មាននោះមិនជះឥទ្ធិពលដល់ចំនួនទឹកប្រាក់ដែលស្ថាប័នទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនក៏ដោយ។ ឧទាហរណ៍មួយនៃតម្រូវការក្នុងការធ្វើបច្ចុប្បន្នភាពការលាតត្រដាង គឺនៅពេលដែលមានភស្តុតាងបន្ទាប់ពីកាលបរិច្ឆេទរាយការណ៍អំពីបំណុលយថាហេតុដែលបានកើតមានឡើងនាកាលបរិច្ឆេទរាយការណ៍។ បន្ថែមពីលើការពិចារណាថាតើស្ថាប័នគួរទទួលស្គាល់សំវិធានធនឥលូវនេះដែរឬយ៉ាងណា, ស្ថាប័នធ្វើបច្ចុប្បន្នភាពការលាតត្រដាងរបស់ខ្លួនអំពីបំណុលយថាហេតុ បន្ទាប់ពីទទួលបានភស្តុតាងនោះ។

## ការលាតត្រដាងអំពីព្រឹត្តិការណ៍មិនកែតម្រូវ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍

**៣០. ប្រសិនបើព្រឹត្តិការណ៍មិនកែតម្រូវ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ មានភាពជាសារវន្ត, ការមិនលាតត្រដាងអាចជះឥទ្ធិពលដល់សេចក្តីសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ ដែលផ្អែកលើមូលដ្ឋាននៃរបាយការណ៍ហិរញ្ញវត្ថុ។ ដូចនេះ ស្ថាប័នមួយត្រូវលាតត្រដាងដូចខាងក្រោមសម្រាប់ខ្ទង់ជាសារវន្តនីមួយៗនៃព្រឹត្តិការណ៍មិនកែតម្រូវ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍៖**

**(ក) ចរិតលក្ខណៈនៃព្រឹត្តិការណ៍ និង**

**(ខ) ការប៉ាន់ស្មានអំពីផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុនៃព្រឹត្តិការណ៍នោះ ឬ របាយការណ៍ដែលបង្ហាញថា ការប៉ាន់ស្មានបែបនេះ មិនអាចត្រូវបានធ្វើឡើង។**

៣១. ខាងក្រោមគឺជាឧទាហរណ៍នៃព្រឹត្តិការណ៍មិនកែតម្រូវ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ ដែលជាទូទៅអាចនាំឱ្យមានការលាតត្រដាង៖

(ក) ការធ្លាក់ចុះខ្លាំងខុសពីធម្មតានៃតម្លៃទ្រព្យដែលគិតតាមតម្លៃសមស្រប ដែលការធ្លាក់ចុះនោះមិនជាប់ពាក់ព័ន្ធនឹងលក្ខខណ្ឌនៃទ្រព្យនាកាលបរិច្ឆេទរាយការណ៍នោះទេ ប៉ុន្តែអាស្រ័យទៅលើកាលៈទេសៈដែលបានកើតឡើង ចាប់តាំងពីកាលបរិច្ឆេទរាយការណ៍

(ខ) ស្ថាប័នសម្រេចចិត្ត បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ ផ្តល់ ឬ បែងចែកអត្ថប្រយោជន៍បន្ថែមច្រើននាពេលអនាគត ដោយផ្ទាល់ ឬ ប្រយោល ទៅកាន់អ្នកចូលរួមកម្មវិធីសេវាសហគមន៍ដែលស្ថាប័នដំណើរការ ហើយអត្ថប្រយោជន៍បន្ថែមទាំងនោះមានផលប៉ះពាល់ចម្បងទៅលើស្ថាប័ន

(គ) ការរួមបញ្ចូលវិស័យសាធារណៈចម្បងៗ (ស្តង់ដា CPSAS ៤០ *ការរួមបញ្ចូលវិស័យសាធារណៈ* តម្រូវឱ្យមានការលាតត្រដាងដាក់លាក់ក្នុងករណីបែបនេះ), ការបញ្ចេញចោលនូវស្ថាប័នក្រោមការគ្រប់គ្រងចម្បងមួយ ឬ ការផ្ទេរសកម្មភាពទាំងអស់ ឬ សកម្មភាពមួយផ្នែកធំដែលស្ថាប័នកំពុងធ្វើ ទៅឱ្យសេវាខាងក្រៅ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍

(ឃ) ការប្រកាសអំពីផែនការបញ្ឈប់ប្រតិបត្តិការ ឬ កម្មវិធីសំខាន់, ការបញ្ចេញចោលនូវទ្រព្យសកម្ម ឬ ការទូទាត់សងបំណុលដែលបង្កឡើងដោយប្រតិបត្តិការ ឬ កម្មវិធីសំខាន់ដែលបានបញ្ឈប់ ឬ កម្មវិធីសំខាន់ ឬ ការចុះកិច្ចព្រមព្រៀងដែលត្រូវអនុវត្ត ដើម្បីលក់ទ្រព្យសកម្ម ឬ ទូទាត់សងបំណុលទាំងនោះ

(ង) ការទិញ ឬ ការបញ្ចេញចោលសំខាន់ៗនូវទ្រព្យសកម្ម

(ច) ការបំផ្លាញអាគារសំខាន់ដោយអគ្គិភ័យ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍

(ឆ) ការប្រកាស ឬ ការចាប់ផ្តើមការអនុវត្តការរៀបចំរចនាសម្ព័ន្ធសំខាន់ឡើងវិញ (សូមមើលស្តង់ដា CPSAS ១៩)

(ជ) ការផ្តួចផ្តើមអំពីច្បាប់ក្នុងការអនុគ្រោះឥណទានដែលបានផ្តល់ឱ្យស្ថាប័ន ឬ បុគ្គលដែលជាផ្នែកមួយនៃកម្មវិធី

(ឈ) ការផ្លាស់ប្តូរទ្រង់ទ្រាយធំមិនធម្មតា បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ អំពីតម្លៃទ្រព្យសកម្ម ឬ អត្រាប្តូរប្រាក់បរទេស

(ញ) ក្នុងករណីដែលស្ថាប័នមានការទទួលខុសត្រូវចំពោះពន្ធលើប្រាក់ចំណូល ឬ ពន្ធប្រហាក់ប្រហែលនឹងពន្ធលើប្រាក់ចំណូល, ការផ្លាស់ប្តូរអត្រាពន្ធ ឬ ច្បាប់ពន្ធដែលបានអនុម័តរួច ឬ បានប្រកាសរួច បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ ដែលមានផលប៉ះពាល់ជាដុំកំភួនលើទ្រព្យសកម្មនិងបំណុលពន្ធបច្ចុប្បន្ន ព្រមទាំងទ្រព្យសកម្មនិងបំណុលពន្ធពន្យារ (ការណែនាំអំពីគណនេយ្យកម្មសម្រាប់ពន្ធលើប្រាក់ចំណូល អាចរកបានក្នុងស្តង់ដាគណនេយ្យជាតិ ឬ អន្តរជាតិ ដែលជាប់ពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល)

(ដ) ការឈានចូលទៅក្នុងកាតព្វកិច្ចជាដុំកំភួន ឬ បំណុលយថាហេតុ ឧទាហរណ៍ តាមរយៈការបោះផ្សាយនូវការធានាជាដុំកំភួន បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ និង

(ឋ) ការចាប់ផ្តើមនូវការដោះស្រាយវិវាទធំៗដែលកើតចេញពីព្រឹត្តិការណ៍ដែលបានកើតឡើងបន្ទាប់ពីកាលបរិច្ឆេទរាយការណ៍។

## CPSAS 14—EVENTS AFTER THE REPORTING DATE


### Acknowledgment

Cambodian Public Sector Accounting Standard 14, is prepared based on the International Public Sector Accounting Standard 14, *Events After the Reporting Date*, extract from the *Handbook of International Public Sector Accounting Pronouncement* of the International Public Sector Accounting Standards Board (IPSASB), published by the International Federation of Accountants (IFAC) in July 2020 and used with a permission of the International Federation of Accountants.


*Handbook of International Public Sector Accounting Pronouncement* ©2020 by the International Federation of Accountants (IFAC). All rights reserved.

Issued by:
Accounting and Auditing Regulator
Street 92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh
Phone: +(855) 23 882 111
Email: info@acar.gov.kh
Website: www.acar.gov.kh

# CPSAS 14 — EVENTS AFTER THE REPORTING DATE

## CONTENTS

Paragraph

Objective……………………………………………………………………………………………………1

Scope……………………………………………………………………………………………………2–4

Definitions……………………………………………………………………………………………………5

Authorizing the Financial Statements for Issue……………………………………………6–8

Recognition and Measurement ……………………………………………………………9–16

Adjusting Events after the Reporting Date ………………………………………… 10–11

Non-Adjusting Events after the Reporting Date ……………………………………12–13

Dividends or Similar Distributions ……………………………………………………14–16

Going Concern……………………………………………………………………………17–25

Restructuring ………………………………………………………………………………25

Disclosure ………………………………………………………………………………26–31

Disclosure of Date of Authorization for Issue…………………………………………26–27

Updating Disclosure about Conditions at the Reporting Date………………… 28–29

Disclosure of Non-Adjusting Events after the Reporting Date………………… 30–31

## Objective

1. The objective of this Standard is to prescribe:

   (a) When an entity should adjust its financial statements for events after the reporting date; and

   (b) The disclosures that an entity should give about the date when the financial statements were authorized for issue, and about events after the reporting date.

   The Standard also requires that an entity should not prepare its financial statements on a going concern basis if events after the reporting date indicate that the going concern assumption is not appropriate.

## Scope

2. **An entity that prepares and presents financial statements under the accrual basis of accounting shall apply this Standard in the accounting for, and disclosure of, events after the reporting date.**

3. [Deleted]

4. [Deleted]

## Definitions

5. **The following terms are used in this Standard with the meanings specified**:

   <u>Events after the reporting date</u> **are those events, both favorable and unfavorable, that occur between the reporting date and the date when the financial statements are authorized for issue. Two types of events can be identified:**

   (a) **Those that provide evidence of conditions that existed at the reporting date (adjusting events after the reporting date); and**

   (b) **Those that are indicative of conditions that arose after the reporting date (non-adjusting events after the reporting date).**

   **Terms defined in other CPSASs are used in this Standard with the same meaning as in those Standards, and are reproduced in the *Glossary of Defined Terms* published separately.**

## Authorizing the Financial Statements for Issue

6. In order to determine which events satisfy the definition of events after the reporting date, it is necessary to identify both the reporting date and the date on which the financial statements are authorized for issue. The reporting date is the last day of the reporting period to which the financial statements relate. The date of authorization for issue is the date on which the financial statements have received approval from the individual or

body with the authority to finalize those statements for issue. The audit opinion is provided on those finalized financial statements. Events after the reporting date are all events, both favorable and unfavorable, that occur between the reporting date and the date when the financial statements are authorized for issue, even if those events occur after (a) the publication of an announcement of the surplus or deficit, (b) the authorization of the financial statements of a controlled entity, or (c) publication of other selected information relating to the financial statements.

7. The process involved in preparing and authorizing the financial statements for issue may vary for different types of entities within and across jurisdictions. It can depend upon the nature of the entity, the governing body structure, the statutory requirements relating to that entity, and the procedures followed in preparing and finalizing the financial statements. Responsibility for authorization of financial statements of individual government agencies may rest with the head of the central finance agency (or the senior finance official/accounting officer, such as the controller or accountant-general). Responsibility for authorization of consolidated financial statements of the government as a whole may rest jointly with the head of the central finance agency (or the senior finance official, such as the controller or accountant- general) and the finance minister (or equivalent).

8. In some cases, as the final step in the authorization process, an entity is required to submit its financial statements to another body (for example, a legislative body such as Parliament or a local council). This body may have the power to require changes to the audited financial statements. In other cases, the submission of statements to the other body may be merely a matter of protocol or process, and that other body may not have the power to require changes to the statements. The date of authorization for issue of the financial statements will be determined in the context of the particular jurisdiction.

## Recognition and Measurement

9. In the period between the reporting date and the date of authorization for issue, elected government officials may announce a government's intentions in relation to certain matters. Whether or not these announced government intentions would require recognition as adjusting events would depend upon (a) whether they provide more information about the conditions existing at reporting date, and (b) whether there is sufficient evidence that they can and will be fulfilled. In most cases, the announcement of government intentions will not lead to the recognition of adjusting events. Instead, they would generally qualify for disclosure as non-adjusting events.

### Adjusting Events after the Reporting Date

10. **An entity shall adjust the amounts recognized in its financial statements to reflect adjusting events after the reporting date.**

11. The following are examples of adjusting events after the reporting date that require an entity to adjust the amounts recognized in its financial statements, or to recognize items that were not previously recognized:

   (a) The settlement after the reporting date of a court case that confirms that the entity had a present obligation at the reporting date. The entity adjusts any previously recognized provision related to this court case in accordance with CPSAS 19, *Provisions, Contingent Liabilities and Contingent Assets*, or recognizes a new provision. The entity does not merely disclose a contingent liability because the settlement provides additional evidence that would be considered in accordance with paragraph 24 in CPSAS 19.

   (b) The receipt of information after the reporting date indicating that an asset was impaired at the reporting date, or that the amount of a previously recognized impairment loss for that asset needs to be adjusted. For example:

      (i) The bankruptcy of a debtor that occurs after the reporting date usually confirms that the debtor was credit-impaired at the end of the reporting period; and

      (ii) The sale of inventories after the reporting date may give evidence about their net realizable value at the reporting date;

   (c) The determination after the reporting date of the cost of assets purchased, or the proceeds from assets sold, before the reporting date;

   (d) The determination after the reporting date of the amount of revenue collected during the reporting period to be shared with another government under a revenue-sharing agreement in place during the reporting period;

   (e) The determination after the reporting date of performance bonus payments to be made to staff if the entity had a present legal or constructive obligation at the reporting date to make such payments as a result of events before that date; and

   (f) The discovery of fraud or errors that show that the financial statements were incorrect.

**Non-adjusting Events after the Reporting Date**

12. **An entity shall not adjust the amounts recognized in its financial statements to reflect non-adjusting events after the reporting date.**

13. The following are examples of non-adjusting events after the reporting date:

   (a) Where an entity has adopted a policy of regularly revaluing property to fair value, a decline in the fair value of property between the reporting date and the date when the financial statements are authorized for issue. The fall in fair value does not normally relate to the condition of the property at the reporting date,

but reflects circumstances that have arisen in the following period. Therefore, despite its policy of regularly revaluing, an entity would not adjust the amounts recognized in its financial statements for the properties. Similarly, the entity does not update the amounts disclosed for the property as at the reporting date, although it may need to give additional disclosure under paragraph 29; and

(b) Where an entity charged with operating particular community service programs decides after the reporting date, but before the financial statements are authorized, to provide/distribute additional benefits directly or indirectly to participants in those programs. The entity would not adjust the expenses recognized in its financial statements in the current reporting period, although the additional benefits may meet the conditions for disclosure as non-adjusting events under paragraph 29.

**Dividends or Similar Distributions**

14. **If an entity declares dividends or similar distributions after the reporting date, the entity shall not recognize those distributions as a liability at the reporting date.**

15. Dividends may arise in the public sector when, for example, a public sector entity controls and consolidates the financial statements of a commercial public sector entity that has outside ownership interests to whom it pays dividends. In addition, some public sector entities adopt a financial management framework, for example "purchaser provider" models, that require them to pay income distributions to their controlling entity, such as the central government.

16. If dividends or similar distributions to owners are declared (i.e., the dividends or similar distributions are appropriately authorized and no longer at the discretion of the entity) after the reporting date but before the financial statements are authorized for issue, the dividends or similar distributions are not recognized as a liability at the reporting date because no obligation exists at that time. Such dividends or similar distributions are disclosed in the notes in accordance with CPSAS 1. Dividends and similar distributions do not include a return of capital.

## Going Concern

17. The determination of whether the going concern assumption is appropriate needs to be considered by each entity. However, the assessment of going concern is likely to be of more relevance for individual entities than for a government as a whole. For example, an individual government agency may not be a going concern because the government of which it forms part has decided to transfer all its activities to another government agency. However, this restructuring has no impact upon the assessment of going concern for the government itself.

18. **An entity shall not prepare its financial statements on a going concern basis if those responsible for the preparation of the financial statements or the governing body determine after the reporting date either (a) that there is an intention to liquidate the entity or to cease operating, or (b) that there is no realistic alternative but to do so.**

19. In assessing whether the going concern assumption is appropriate for an individual entity, those responsible for the preparation of the financial statements, and/or the governing body, need to consider a wide range of factors. Those factors will include the current and expected performance of the entity, any announced and potential restructuring of organizational units, the likelihood of continued government funding and, if necessary, potential sources of replacement funding.

20. In the case of entities whose operations are substantially budget-funded, going concern issues generally only arise if the government announces its intention to cease funding the entity.

21. Some public sector entities may be required to be fully or substantially self- funding, and to recover the cost of goods and services from users. For any such entity, deterioration in operating results and financial position after the reporting date may indicate a need to consider whether the going concern assumption is still appropriate.

22. If the going concern assumption is no longer appropriate, this Standard requires an entity to reflect this in its financial statements. The impact of such a change will depend upon the particular circumstances of the entity, for example, whether operations are to be transferred to another government entity, sold, or liquidated. Judgment is required in determining whether a change in the carrying value of assets and liabilities is required.

23. When the going concern assumption is no longer appropriate, it is also necessary to consider whether the change in circumstances leads to the creation of additional liabilities or triggers clauses in debt contracts leading to the reclassification of certain debts as current liabilities.

24. CPSAS 1 requires certain disclosures if:

    (a) The financial statements are not prepared on a going concern basis. CPSAS 1 requires that when the financial statements are not prepared on a going concern basis, this must be disclosed, together with the basis on which the financial statements are prepared and the reason why the entity is not considered to be a going concern; or

    (b) Those responsible for the preparation of the financial statements are aware of material uncertainties related to events or conditions that may cast significant doubt upon the entity's ability to continue as a going concern. The events or conditions requiring disclosure may arise after the reporting date. CPSAS 1 requires such uncertainties to be disclosed.

**Restructuring**

25. Where a restructuring announced after the reporting date meets the definition of a non-adjustable event, the appropriate disclosures are made in accordance with this Standard. Guidance on the recognition of provisions associated with restructuring is found in CPSAS 19. Simply because a restructuring involves the disposal of a component of an entity, this does not in itself bring into question the entity's ability to continue as a going concern. However, where a restructuring announced after the reporting date means that an entity is no longer a going concern, the nature and amount of assets and liabilities recognized may change.

## Disclosure

### Disclosure of Date of Authorization for Issue

26. **An entity shall disclose the date when the financial statements were authorized for issue and who gave that authorization. If another body has the power to amend the financial statements after issuance, the entity shall disclose that fact.**

27. It is important for users to know when the financial statements were authorized for issue, as the financial statements do not reflect events after this date. It is also important for users to know of the rare circumstances in which any persons or organizations have the authority to amend the financial statements after issuance. Examples of individuals or bodies that may have the power to amend the financial statements after issuance are Ministers, the government of which the entity forms part, Parliament, or an elected body of representatives. If changes are made, the amended financial statements are a new set of financial statements.

### Updating Disclosure about Conditions at the Reporting Date

28. **If an entity receives information after the reporting date, but before the financial statements are authorized for issue, about conditions that existed at the reporting date, the entity shall update disclosures that relate to these conditions in the light of the new information.**

29. In some cases, an entity needs to update the disclosures in its financial statements to reflect information received after the reporting date but before the financial statements are authorized for issue, even when the information does not affect the amounts that the entity recognizes in its financial statements. One example of the need to update disclosures is when evidence becomes available after the reporting date about a contingent liability that existed at the reporting date. In addition to considering whether it should now recognize a provision, an entity updates its disclosures about the contingent liability in the light of that evidence.

### Disclosure of Non-adjusting Events after the Reporting Date

30. **If non-adjusting events after the reporting date are material, non-disclosure could influence the economic decisions of users taken on the basis of the financial statements. Accordingly, an entity shall disclose the following for each material category of non-adjusting event after the reporting date:**

    (a) **The nature of the event; and**

    (b) **An estimate of its financial effect, or a statement that such an estimate cannot be made.**

31. The following are examples of non-adjusting events after the reporting date that would generally result in disclosure:

    (a) An unusually large decline in the value of property carried at fair value, where that decline is unrelated to the condition of the property at reporting date, but is due to circumstances that have arisen since the reporting date;

    (b) The entity decides after the reporting date, to provide/distribute substantial additional benefits in the future directly or indirectly to participants in community service programs that it operates, and those additional benefits have a major impact on the entity;

    (c) A major public sector combination (CPSAS 40, *Public Sector Combinations* requires specific disclosures in such cases), a disposal of a major controlled entity or the outsourcing of all or substantially all of the activities currently undertaken by an entity after the reporting date;

    (d) Announcing a plan to discontinue an operation or major program, disposing of assets, or settling liabilities attributable to a discontinued operation or major program, or entering into binding agreements to sell such assets or settle such liabilities;

    (e) Major purchases and disposals of assets;

    (f) The destruction of a major building by a fire after the reporting date;

    (g) Announcing, or commencing the implementation of, a major restructuring (see CPSAS 19);

    (h) The introduction of legislation to forgive loans made to entities or individuals as part of a program;

    (i) Abnormally large changes after the reporting date in asset prices or foreign exchange rates;

    (j) In the case of entities that are liable for income tax or income tax equivalents, changes in tax rates or tax laws enacted or announced after the reporting date that have a significant effect on current and deferred tax assets and liabilities (guidance on accounting for income taxes can be found in the relevant international or national accounting standard dealing with income taxes);

    (k) Entering into significant commitments or contingent liabilities, for example, by issuing significant guarantees after the reporting date; and

    (l) Commencing major litigation arising solely out of events that occurred after the reporting date.

**និយ័តករគណនេយ្យនិងសវនកម្ម**
ផ្លូវលេខ ៩២, សង្កាត់វត្តភ្នំ, ខណ្ឌដូនពេញ, រាជធានីភ្នំពេញ
លេខទូរស័ព្ទ÷ +(855) 23 882 111
អ៊ីម៉ែល÷ info@acar.gov.kh
គេហទំព័រ÷ www.acar.gov.kh

ន.គ.ស. រក្សាសិទ្ធិក្នុងការកែប្រែស្តង់ដាទៅតាមការវិវត្តក្នុងក្របខណ្ឌអន្តរជាតិ